# តំបន់ផ្ទៃរងទឹកភ្លៀងទន្លេស្រែពកខាងលើ A1, A3 & A4i



**ខេត្ត** : រតនគិរី និង មណ្ឌលគិរី

**ស្រុក** : លំផាត់ យ៉ាដាវ កោះញែក និង ពេជ្ររាដា

**ផ្ទៃដី ( ហិកតា)** : ៥០៧.៧១១

**រយៈកំពស់ ( ម៉ែត្រ)** : ៩២ ដល់ ៦៥១

**កូអរដោនេចំណុចកណ្ដាល** : ១២$^{0}$ ៥៨´ ជ ១០៧$^{0}$ ១៦´ ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានតំបន់ផ្ទៃរងទឹកភ្លៀងទន្លេស្រែពកផ្នែកខាងលើនៃ ទីរួមស្រុកលំផាត់ ដោយមិនបញ្ចូលតំបន់នៅខាងក្រៅមួយចំនួនដែលមានទីជំរកបាត់បង់យ៉ាងច្រើននោះទេ ។ តាមលក្ខណៈសណ្ឋានដី តំបន់នេះមានលក្ខណៈរាបស្មើ ទោះបីជាមានកូនភ្នំទាបៗមួយចំនួនដែលស្ថិតនៅព័ទ្ធជុំវិញភ្នំយ៉ាងកែក៏ដោយ ។ រុក្ខជាតិនៅក្នុងតំបន់នេះគ្របដណ្តប់លើសលប់ដោយព្រៃរបោះលាយឡំជាមួយតំបន់តូចៗនៃព្រៃពាក់កណ្តាលស្រោង ។ លើសពីនេះទៀត តំបន់នេះមានតំបន់ដីសើមយ៉ាងច្រើន ដូចជាទន្លេស្រែពក ដៃរបស់វា និង បឹងដែលកើតឡើងដោយការកាត់ផ្តាច់ពីទន្លេ (Oxbow lakes) ព្រមទាំងអូរជាច្រើនទៀត ខ្លះមានទឹកតាមរដូវកាល និង ខ្លះមានទឹកជាអចិន្ត្រៃយ៍ក្នុងអំឡុងពេលរដូវប្រាំង ។ មានត្រពាំងជាច្រើន និង វាលស្មៅលិចទឹកតាមរដូវកាល ដែលមានទទឹងប្រហែលពីបីម៉ែត្ររហូតដល់រាប់រយម៉ែត្រ ។ នៅប៉ែកពាយ័ព្យនៃតំបន់ IBA ត្រូវរួមបញ្ចូលទាំងតំបន់ទីជំរកសត្វព្រៃលំផាត់ រីឯនៅប៉ែកខាងត្បូងត្រូវរួមបញ្ចូលតំបន់ព្រៃអភិរក្សធនធានសេនេទិច និង សត្វព្រៃ ។

តំបន់ IBA នេះបានទ្រទ្រង់ពពួកសត្វស្លាបសំខាន់ៗរស់នៅក្នុងតំបន់ព្រៃរបោះ ក្នុងតំបន់ឥណ្ឌូចិនភាគកណ្តាល ។ ពពួកថនិកសត្វធំៗមានក្រចកជំពាមក៏សម្បូរផងដែរនៅក្នុងតំបន់នេះមានន័យថា តំបន់នេះមានសក្តានុពលយ៉ាងធំធេងក្នុងការទ្រទ្រង់ប្រភេទត្មាតផេះ ត្មាតត្នោត និង ត្មាតភ្លើង ដែលចំនួនរបស់វាមានច្រើនជាងតំបន់ផ្សេងៗនៅក្នុងតំបន់អាស៊ីអគ្នេយ៍ ។ លើសពីនេះទៀត ទន្លេស្រែពកគឺជាទន្លេមួយក្នុងចំណោមតំបន់ពីរ ឬ បីកន្លែងនៅក្នុងប្រទេសកម្ពុជា ដែលទ្រទ្រង់ប្រភេទពពួលទឹក ទាព្រៃស្លាបស (មានកំណត់ត្រាតែម្តងគត់ពីតំបន់ IBA នេះ) ប៉ុន្តែតាមលក្ខណៈទីជំរកនៅក្នុងតំបន់នេះអាចមានលក្ខណៈសមស្របក្នុងការទ្រទ្រង់ប្រភេទទាព្រៃស្លាបសនេះ ។ មានកំណត់ត្រាតែម្តងគត់អំពីត្រយ៉ងចំកំកសនៅក្នុងតំបន់នេះ ប៉ុន្តែស្ថានភាពពិតប្រាកដរបស់ប្រភេទនេះនៅតែមិនទាន់បានដឹងនៅឡើយ ។ ជាចុងក្រោយ មានកំណត់ត្រាតែម្តងគត់នៃប្រភេទពពូលក្បាលព្រលែតពីតាមបណ្តោយអូរដាកដាម (Dak Dam) ដែលជាអូរនៅតាមព្រំដែនរវាងប្រទេសកម្ពុជា និង វៀតណាម ។ ទោះជាយ៉ាងក្តីប្រភេទនេះមិនទាន់ត្រូវបានគេដឹងពិតប្រាកដនៅឡើយទេ ថាតើវាត្រូវបានគេកត់ត្រានៅត្រង់ផ្នែកណានៃអូរនេះ ហើយប្រហែលវាអាចមានផងដែរនៅក្នុងតំបន់ស្នួល / កែវសីមា / អូររាំង (KH027) ។ រីឯស្ថានភាពពិតប្រាកដរបស់ត្រយ៉ងចំកំកសមិនទាន់ត្រូវបានគេដឹងច្បាស់លាស់នៅឡើយទេ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ក្ងោក | Green Peafowl | *Pavo muticus* | A1 |
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 |

| | | | | |
|---|---|---|---|---|
| ក្រៀល | Sarus Crane | *Grus antigone* | A1 | |
| ត្មាតត្នោត | Long-billed Vulture | *Gyps indicus* | A1 | |
| ត្មាតផេះ | White-rumped Vulture | *Gyps bengalensis* | A1 | |
| ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | A1 | |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | |
| ត្រយ៉ងចំកំក ស | White-shouldered Ibis | *Pseudibis davisoni* | A1 | |
| ត្រយ៉ងយក្ស | Giant Ibis | *Pseudibis gigantea* | A1 | A4i |
| ទាព្រៃស្លាប ស | White-winged Duck | *Cairina scutulata* | A1 | |
| ពពូលទឹក | Masked Finfoot | *Heliopais personata* | A1 | |
| ស្ទាញ | Darter | *Anhinga melanogaster* | A1 | |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 | |
| អកត្រីតូច | Lesser Fish Eagle | *Ichthyophaga humilis* | A1 | |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ ពីរប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង ប្រាំបួនប្រភេទរស់ក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរថនិកទទួលរងការគំរាមកំហែងពិភពលោក**

ស្វាត្រោស ស្វាក្តាម ស្វាព្រាម និង ស្វាក្រវាត់ ។

**ដំរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

ដំរី រមាំង ខ្ទីង ទន្សោង និង ក្របីព្រៃ ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

ក្រពើទន្លេ (ក្រពើត្រី) អណ្តើកបិទមុខស្លឹកខ្មៅ អណ្តើកសោមញី អណ្តើកក្របីក្បាលលឿង អណ្តើកព្រិច កន្ធាយអាស៊ី និង កន្ធាយក្បាលកង្កែប ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការគំរាមកំហែងចំបងដែលនៅតែបន្តកើតមាននៅក្នុងតំបន់នេះគឺការបរបាញ់ដែលធ្វើឱ្យមានការគំរាមកំហែងទៅលើពពួកកេងកង សេក ពពូល និង ក្ងោក ។ ការបរបាញ់ក៏ជាការគំរាមកំហែងមួយដោយប្រយោលផងដែរទៅលើពពួកត្មាត ដោយពពួកសត្វក្រចកជំពាមទាំងនោះជាប្រភពចំណីដ៏សំខាន់របស់ពួកវា ។ នៅតាមបណ្តោយដងទន្លេស្រែពក ការកាប់ព្រៃឈើ និង ការរានដីព្រៃសម្រាប់ធ្វើដំណាំកសិកម្ម បានកើតឡើងនៅតាមមាត់ទន្លេ ហើយសកម្មភាពនេសាទត្រីបំផ្លិចបំផ្លាញបានកើតឡើងផងដែរ ជាពិសេសការប្រើប្រាស់ថ្នាំពុល និង គ្រឿងផ្ទុះផ្សេងៗ គឺជាការព្រួយបារម្ភផងដែរ ។ ការគំរាមកំហែងទាំងអស់ដែលកើតឡើងក្នុងតំបន់នេះអាចធ្វើឱ្យប៉ះពាល់ដល់ប្រភេទពពូលទឹក និង សត្វស្លាបទាំងឡាយដែលរកស៊ីនៅតាមប្រព័ន្ធទន្លេ ។

## អនុសាសន៍

វិធានការទាំងឡាយដើម្បីបង្ក្រាបការបរបាញ់ និង ការធ្វើពាណិជ្ជកម្មសត្វព្រៃត្រូវតែអនុវត្តគ្រប់តំបន់ ។ ការងារនេះគួរតែចាប់ផ្ដើមដោយបង្កើតឡើងប្រព័ន្ធល្បាតនៅក្នុងតំបន់ព្រៃអភិរក្សខេត្តមណ្ឌលគីរី ។

តំបន់ស្នូលនៅផ្នែកខាងលើទន្លេស្រែពក ប្រហែលស្ថិតនៅខាងលិចអូរច្បារ ហើយទន្លេនៅប៉ែកខាងជើង និង ខាងត្បូងរហូតដល់ព្រំដែនវៀតណាមគួរតែការពារឱ្យបានតឹងរឹងក្រោមរចនាសម្ព័ន្ធមានស្រាប់នៃតំបន់ព្រៃការពារ ។

ការអភិរក្សផ្នែកសំខាន់ៗនៃកំណាត់ទន្លេស្រែពកគួរតែមានការគ្រប់គ្រងផ្នែកទាំងមូលនៃតំបន់អភិរក្សមានស្រាប់ ។ ទោះជាយ៉ាងណាក៏ដោយ ការងារនេះត្រូវតែពិនិត្យមើលទ្រង់ទ្រាយប្រវែងរបស់ប្រព័ន្ធទន្លេទាំងអស់ ដែលជាប់ជាមួយនឹងដែនជំរកសត្វព្រៃលំផាត់ (KH024) ដោយផ្ដោតលើផ្នែកសំខាន់ៗរបស់ទន្លេដែលអាចទទួលរងភាពមហន្តរាយ ។

ការសិក្សាស្រាវជ្រាវបន្ថែមតាមដងទន្លេស្រែពក និង ដៃរបស់វាចាំបាច់ត្រូវធ្វើឡើងដោយផ្ដោតលើការកំណត់ផ្នែកសំខាន់ៗរបស់ព្រៃដុះតាមប្រព័ន្ធទន្លេ និង កំណត់ឱ្យបានច្បាស់លាស់នូវចំនួនកន្លែងពងកូនរបស់ពពួកសត្វដែលពងកូនលើវាលខ្សាច់ ។

ការខិតខំប្រឹងប្រែងគួរតែយកចិត្តទុកដាក់លើការការពារប្រភេទសត្វដែលពងកូនលើវាលខ្សាច់ ខណៈដែលពួកវាកំពុងពងកូន ។ កិច្ចព្រមព្រៀងសហគមន៏គួរតែបង្កើតឡើងតាមភូមិនិមួយៗ ដើម្បីឱ្យតំបន់ពងកូនទាំងនោះមិនមានការរំខាន ។

ជនអន្តោប្រវេសន៏ ការតាំងទីលំនៅខុសច្បាប់ និង ការទន្ទ្រានយកដីនៅក្នុងតំបន់សំខាន់ៗនៃតំបន់ IBAគួរតែហាមឃាត់ ។

ការបោះទីតាំងភូមិថ្មីៗ និង ការអភិវឌ្ឍន៏កសិកម្មតាមបណ្ដោយដងទន្លេស្រែពកមិនគួរត្រូវបានលើកទឹកចិត្តឡើយ ហើយផ្នែកសំខាន់ៗនៃព្រៃដុះតាមប្រព័ន្ធទន្លេដែលគេបានកំណត់រួចហើយនោះគួរតែការពារឱ្យតឹងរឹងពីការកាប់រំលំ និង ការធ្វើកសិកម្មពនេចរ ។

## ឯកសារយោង


Barzen, J. (2001) Waterbirds and wetlands of northern Cambodia. *Bugle* 27(4): 1-2.

Barzen, J. (2002) Waterbirds and wetlands of northern Cambodia. *Cambodia Bird News* 9:36-38.

Brickle, N. W., Nguyen Cu, Ha Quy Quynh, Nguyen Thai Tu Cuong and Hoang Van San (1998) *The status and distribution of Green Peafowl* Pavo muticus *in Dak Lak province, Vietnam*. Hanoi: BirdLife International Vi etnam Programme.

Davidson, P., Poole, C. M. and Duckworth J. W. (2001) Mekong Wagtail (*Motacilla samvaesnae*): the great river's only known avian endemic. *Bull. Oriental Bird Club* 34: 56-59.

Duckworth, J. W., Alström, P., Davidson, P., Evans, T. D., Poole, C. M., Tan Setha and Timmins, R. J. (2001) A new species of wagtail from the lower Mekong basin. *Bull. Brit. Ornith. Club* 121(3): 152-182.

Goes, F. (1999) Notes on selected bird species in Cambodia. *Forktail* 15: 25-27.

Long, B., Swan, S. R. and Kry Masphal (2000) Biological surveys in northeast Mondulkiri, Cambodia. Hanoi and Phnom Penh: Fauna & Flora International and the Wildlife Protection Office.

Poole, C. M. Duckworth, J. W. and van Zalinge, N. J. (in prep.) Bird observations from the Mekong and major tributaries in north-east Cambodia, 1998-2000.

Tan Setha (2002) Mekong Wagtail *Motacilla samveasnae*: emblem of the riverine birds of northeast Cambodia. *Cambodia Bird News* 9:14-17.

Timmins, R. J. and Men Soriyun (1998) *A wildlife survey of the Tonle San and Tonle Srepok river basins in north-east ern Cambodia.* Hanoi and Phnom Penh: Fauna & Flora International and the Wildlife Protection Office.

Timmins, R. J. and Ou Rattanak (2001) *The importance of Phnom Prich Wildlife Sanctuary and adjacent areas for the conservation of Tigers and other key species*. Phnom Penh: WWF.

van Zalinge, N. J., Poole, C. M., Duckworth, J. W. and Goes, F. (2002) Waterbird counts on the Mekong, Sekong, Sesan and Srepok rivers. *Cambodia Bird News* 9: 18-29.